# ប្រឡងឆមាសលើកទី១
## វិញ្ញាសាៈ ភាសាខ្មែរ

**សាលាបឋមសិក្សា** ……………………

**ថ្នាក់ទី៦**

**ឈ្មោះ**…………………………………………

| ពិន្ទុ | មូលវិចារ |
| --- | --- |
| | |

**I. អំណាន**

ចូរអ្នកអានអត្ថបទខាងក្រោម រួចឆ្លើយនឹងសំណួរ។

### រឿង ទំនៀមទម្លាប់ដាក់ប្រាក់កាក់នៅក្នុងមាត់អ្នកស្លាប់

មានរឿងបុរាណតំណាលតៗគ្នាថា មានបុរសម្នាក់នៅជាមួយប្រពន្ធតាំងពីក្មេងរហូតដល់ចាស់ គ្មានកូនមួយសោះ។ គាត់មានមាសមួយបាត។ ប្ដីប្រពន្ធនេះ បានសន្យាគ្នាថា បើអ្នកណាស្លាប់មុនត្រូវយកមាសនេះ ដាក់ក្នុងមាត់អ្នកនោះ។ ចំណេរកាលមិនយូរប៉ុន្មាន ប្ដីបានស្លាប់មុនទៅ។ ភរិយាក៏យកមាសនោះទៅដាក់ក្នុងមាត់ប្ដី ហើយយកសពប្ដីទៅបូជា។ ភ្លើងឆេះមាសរលាយអស់នៅសល់តែបីស្លឹង។

ថ្ងៃមួយ ព្រះមហាក្សត្របានត្រាស់បង្គាប់ឱ្យរៃអង្គាសមាសក្នុងមួយផ្ទះឱ្យបានមួយបាតជាកំហិត។ ប្រពន្ធរបស់ខ្មោចនោះ ក៏យកមាសបីស្លឹងដែលគាត់រើសទុកនោះ ទៅថ្វាយស្ដេច។ គាត់ទូលស្ដេច ៖ " ក្រាបទូលព្រះករុណា! មាសនេះពីដើមពេញមួយបាត តែខ្ញុំម្ចាស់បានយកទៅបង់មាត់ឱ្យប្ដីខ្ញុំម្ចាស់នៅពេលគាត់ស្លាប់ ក៏ត្រូវភ្លើងឆេះអស់នៅសល់តែប៉ុណ្ណឹង។ សូមព្រះករុណា មេត្តាដល់សត្វទ័លក្រផងចុះ។ ខ្ញុំម្ចាស់មិនអាចរកមាសមកថ្វាយព្រះអង្គបានឡើយ"។ ព្រះមហាក្សត្រទ្រង់ស្ដាប់ហើយ ក៏កើតក្ដីសង្វេគស្លុតព្រះទ័យ ទើបទ្រង់លើកលែងការរៃយកមាសពីបណ្ដារាស្ដ្រតទៅទៀត។

អាស្រ័យរឿងនេះ ទើបបណ្ដារាស្ត្រទាំងអស់យល់ថា ប្រាក់ ឬមាសដែលបង់ក្នុងមាត់ខ្មោច មានអានុភាពទៅលើទឹកចិត្តមនុស្សណាស់ សូម្បីព្រះមហាក្សត្រក៏ចុះចាញ់អានុភាពនេះដែរ។ ម្យ៉ាងទៀត អានុភាពនៃប្រាក់ ឬមាសបង់មាត់ខ្មោចនេះ ជាវត្ថុស័ក្ដិសិទ្ធិអាចជួយរំដោះគ្រោះថ្នាក់ ក្នុងពេលមានអាសន្នបាន។ ហេតុដូច្នេះហើយ ទើបគេនាំគ្នាធ្វើរបៀបនេះ រហូតកើតទៅជាទំនៀមទម្លាប់តរៀងមក។

ប៉ុន្ដែអ្នកប្រាជ្ញបុរាណ ឱ្យយកប្រាក់ ឬមាសទៅដាក់ក្នុងមាត់ខ្មោច ដើម្បីធ្វើជាប្រស្នាឱ្យពិចារណាថា យើងមិនអាចយករបស់អ្វីមួយជាប់នឹងខ្លួនបានទេ នៅពេលដែលយើងស្លាប់ទៅ។

**(ដកស្រង់នឹងកែសម្រួលពីប្រជុំរឿងព្រេងខ្មែរភាគ៩)**

**សំណួរ**

១. តើរឿងនេះមានតួអង្គណាខ្លះ?

……………………………………………………………………………………………

……………………………………………………………………………………………

២. តើប្ដីប្រពន្ធបានសន្យាគ្នាដូចម្ដេច?

……………………………………………………………………………………………

……………………………………………………………………………………………

LIVEWORKSHEETS

៣. តើព្រះមហាក្សត្រត្រាស់បង្គាប់ដូចម្ដេច?

...................................................................................................................................................

...................................................................................................................................................

៤. ហេតុអ្វីបានជាព្រះមហាក្សត្រឈប់រើអង្គាសមាសពីប្រជារាស្ត្រ?

...................................................................................................................................................

...................................................................................................................................................

៥. តើប្រជារាស្ត្រ មានជំនឿដូចម្ដេចចំពោះការយកប្រាក់ ឬមាសទៅបង់នឹងមាត់ខ្មោច?

...................................................................................................................................................

...................................................................................................................................................

៦. តើអ្នកប្រាជ្ញបុរាណចង់អប់រំដូចម្ដេច?

...................................................................................................................................................

...................................................................................................................................................

**II. លំហាត់**

**ក. ចូររកពាក្យន័យដូចនឹងពាក្យខាងដើមជួរ ដោយគូសសញ្ញា √ ក្នុងប្រអប់ និង x ក្នុងប្រអប់ចម្លើយខុស។**

| | | | |
|---|---|---|---|
| ១. ប្រព្រឹត្ត ៖ | ☐ ចូលចិត្ត | ☐ ធ្វើតាម | ☐ ប្រឹងប្រែង |
| ២. ប្រហារ ៖ | ☐ ខឹង | ☐ ចង | ☐ សម្លាប់ |
| ៣. គន្លង ៖ | ☐ លំអាន | ☐ របង | ☐ ព្រំប្រទល់ ។ |

**ខ. ចូររកពាក្យពីរដែលមានន័យដូចគ្នានៅក្នុងជួរនីមួយៗ ។**

| | | | |
|---|---|---|---|
| ១. ត្រកាល ៖ | ☐ ប្រសើរ | ☐ ប្រយ័ត្ន | ☐ ថ្លៃថ្នូ |
| ២. ដេរដាស៖ | ☐ ប្រញឹក | ☐ ពាសពេញ | ☐ រឹករក់ |
| ៣. ត្រកាល ៖ | ☐ បៀតបៀន | ☐ ប្រមាថ | ☐ ប្រមូល ។ |

**គ. ចូររកពាក្យផ្ទុយនឹងពាក្យខាងដើមជួរ ដោយគូសសញ្ញា √ ក្នុងប្រអប់ និង x ក្នុងប្រអប់ចម្លើយខុស។**

| | | | |
|---|---|---|---|
| ១. សាមគ្គី ៖ | ☐ រួបរួម | ☐ បែកបាក់ | ☐ វៀចវេរ |
| ២. អ៊ូអរ ៖ | ☐ ខ្វល់ខ្វាយ | ☐ មមាញឹក | ☐ ប្រមូល ។ |

**ឃ. ចូររកពាក្យដែលមានន័យផ្ទុយគ្នានឹងពាក្យនៅក្នុងជួរនីមួយៗ ។**

| | | | |
|---|---|---|---|
| ១. បុរាណ ៖ | ☐ យូរ | ☐ សម័យ | ☐ ចាស់ |
| ២. សរសើរ ៖ | ☐ បន្ទុះបង្អាប់ | ☐ ញញើត | ☐ កោតក្រែង |
| ៣. អន់ថយ ៖ | ☐ ដុះដាល | ☐ រួសរាយ | ☐ ជឿនលឿន |
| ៤. ទុកចិត្ត ៖ | ☐ ប្រយ័ត្ន | ☐ ធ្វេសប្រហែស | ☐ ជឿជាក់ |
| ៥. ហូរហៀរ៖ | ☐ ចង្អៀត | ☐ ញឹកញាប់ | ☐ ម្តងម្កាល ។ |

LIVEWORKSHEETS

**ង. ចូរយកពាក្យក្នុងប្រអប់ទៅបំពេញចន្លោះខាងក្រោម ។**

| | | | | | | | |
|---|---|---|---|---|---|---|---|
| ឧទ្ទិស | ព្រះពុទ្ធ | ព្រះសង្ឃ | ជំនឿ | ចង្ហាន់ | សន្តាន | សាសនា | បញ្ជូន |

នៅលើសកលលោកមាន ................................ ច្រើន ប៉ុន្តែប្រជាជនកម្ពុជាភាគច្រើនបានប្រកាន់យកសាសនា ................................. ។ នោះគឺដោយសារប្រជាជនយើងមាន ................................. មុតមាំលើព្រះពុទ្ធសាសនា។ នៅថ្ងៃភ្ជុំបិណ្ឌ ខ្មែរយើងយក................................. ទៅប្រគេនព្រះសង្ឃ ដើម្បី.............................កុសលដល់ញាតិ .............................. ដែលបានចែកឋានទៅ។ នេះមកពីយើង មានជំនឿថា ................................ អាចបញ្ជូនកុសល់ដល់ពួកគាត់មែន។

LIVEWORKSHEETS